ទស្សនៈ
អ្នកនិពន្ធ

វ៉ុល២, លេខ១៣, ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០

# ការវិលត្រឡប់ទៅកាន់ភាវៈវិញ៖ ការស្វែងរកភាពជាខ្មែរនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន

អ៊ុន លាង *

នៅក្នុងអត្ថបទនៃទស្សនៈអ្នកនិពន្ធនេះ ខ្ញុំសុំបង្ហាញពីប្រវត្តិដ៏វែងឆ្ងាយ និងទូលំទូលាយអំពី "ការចង់ដឹងចង់ឃើញបែបបញ្ញវន្ត" របស់ខ្ញុំ។ ខ្ញុំស្នើឲ្យអ្នកអាន ឆ្ងល់អំពីបញ្ហាជាមូលដ្ឋានគ្រឹះនៅជុំវិញអត្តិភាពរបស់មនុស្សចេញពីផ្នត់គំនិត "កម្ពុជា" ដែលជាការយល់ដឹងចេញពីការឆ្លុះបញ្ចាំងដោយប្រើកញ្ចក់នៃប្រពៃណីផ្សេងៗ។ ដោយលាយបញ្ចូលគ្នារវាងយុទ្ធសាស្ត្រវិភាគបែបនរវិទ្យា សង្គមវិទ្យា និងប្រវត្តិវិទ្យា *ការប៉ុនប៉ងរបស់ខ្ញុំ គឺស្នើឲ្យបញ្ញវន្តកម្ពុជាធ្វើការរួមគ្នាដើម្បីឆ្លើយនឹងសំណួរដែលប្រទាក់ក្រឡាគ្នាដូចខាងក្រោម ដើម្បីបង្កើតបានជាគ្រឹះសម្រាប់ការសន្ទនាបែបទស្សនវិស័យទស្សនវិជ្ជា ដែលមានការចូលរួម និងឆ្លងប្រទេសអំពីបញ្ហាអត្តិភាព។*

១. តើយុវជនកម្ពុជាបច្ចុប្បន្ន "បង្កើតអត្ថន័យ" អំពីជីវិតរបស់ពួកគេដោយរបៀបណា និងថាតើការបង្កើតអត្ថន័យនេះកំណត់ទំនាក់ទំនងសង្គម និងបុគ្គលដោយរបៀបណា?

២. តើការសន្មត និងលោកទស្សនៈអ្វីដែលជះឥទ្ធិពលលើទំនាក់ទំនងបុគ្គល និងសង្គមនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន?

៣. តើអ្វីទៅដែលអាចជាគ្រឹះនៃសកម្មភាពបុគ្គល និងសង្គមនៅក្នុងបរិបទកម្ពុជានាពេលអនាគត?

ស្ទើរតែគ្រប់ស្នាដៃសិក្សាជាន់ខ្ពស់ផ្នែកប្រវត្តិសាស្ត្រកម្ពុជាផ្តោតតែទៅលើបញ្ហាពីរតែប៉ុណ្ណោះ៖ ការរះត្រដែតឡើង/ការធ្លាក់ចុះនៃអង្គរវត្ត និងការរះត្រដែតឡើង/ការធ្លាក់ចុះនៃរបបខ្មែរក្រហម។ ដូចគ្នាផងដែរ ការស្រាវជ្រាវនាសហសម័យក៏ផ្តោតទាំងស្រុងលើបញ្ហាពីរដែរ៖ ដំណើរការប្រជាធិបតេយ្យនីយកម្ម និងគោលនយោបាយអភិវឌ្ឍន៍។ ទោះបីជាផ្នែកប្រវត្តិសាស្ត្រ ឬសហសម័យ គ្រប់ការសិក្សាស្ទើរតែទាំងអស់ត្រូវបានជះឥទ្ធិពលដោយគំនិតរួមមួយ ប៉ុន្តែជាការសន្មតមួយដែលមិនមានភាពជាក់លាក់ និងមិនមានប្រភពដើមច្បាស់លាស់នោះគឺថា ប្រសិនបើម្នាក់ៗដើរតួនាទីរបស់ខ្លួនឲ្យបានសមស្រប និងដើរតាមគំនិតរួមដែលបានសន្មតនេះដោយមិនចោទសួរអ្វីទាំងអស់ គោលនយោបាយបែបបញ្ញានេះ (ជានិច្ចជាកាល គឺជាគោលនយោបាយដែលចម្លងទាំងស្រុងចេញពីភ្នាក់ងារអភិវឌ្ឍន៍ដែលដឹកមុខដោយបស្ចិមប្រទេស) នឹងនាំសង្គមកម្ពុជាទៅដល់ការអភិវឌ្ឍ ដោយ "ការអភិវឌ្ឍ" ត្រូវបានយល់ថាជា *ស្ទែម* (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) បច្ចេកវិទ្យានីយកម្ម និងឧស្សាហូបនីយកម្ម និងសេដ្ឋកិច្ចទីផ្សារដែលផ្អែកលើវប្បធម៌ប្រើប្រាស់និយម។ សេចក្តីសង្ឃឹមដែលគ្មានគតិបណ្ឌិតនេះជឿថា ដំណាក់កាលចុងក្រោយនៃវឌ្ឍនភាពមនុស្ស ដែលហាក់នៅជិតបង្កើយនេះ គឺជាអ្វីដែលមិនគួរជាបញ្ហាក្នុងការសម្រេចឲ្យ

*លោកបណ្ឌិត **អ៊ុន លាង** គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

បាននោះទេ។ ប៉ុន្តែមានមនុស្សតិចតួចណាស់ដែលឆ្ងល់ពីជម្រៅនៃបញ្ហានេះ។

មានបញ្ញវន្តកម្ពុជា និងអ្នកសិក្សាជាន់ខ្ពស់តិចតួចណាស់ដែលបានពិនិត្យមើលការប្រែប្រួលសង្គម សេដ្ឋកិច្ច និងនយោបាយនៅកម្ពុជាប្រកបដោយការរិះគន់ (ជាឧទាហរណ៍ ដែលកំពុងធ្វើដំណើរយ៉ាងលឿន និងយ៉ាងជ្រៅចូលទៅក្នុង*សភាពមិនច្បាស់លាស់/ប្រប្រូកប្រឬល់*។ តាមទស្សនវិស័យទស្សនវិជ្ជានៅសម្បកខាងក្រៅ កម្ពុជាត្រូវបានមើលឃើញជានិម្មិតរូបនៃ "ប្រទេសកំពុងអភិវឌ្ឍន៍" ប៉ុន្តែនៅខាងក្នុង ភាពមិនច្បាស់លាស់/ប្របូកប្របល់កំពុងរីកធំឡើងៗ។ ពលរដ្ឋកម្ពុជាកំពុងធ្វើដំណើរលឿនទៅៗ ទៅក្នុងពិភពមិនច្បាស់លាស់/ប្របូកប្របល់។ មួយផ្នែកធំនៃបញ្ហាគឺថា ពួកគេត្រូវបានកាត់ផ្តាច់យ៉ាងឃោរឃៅព្រៃផ្សៃចេញពីប្រវត្តិសាស្ត្រ និងធនធានបញ្ញាជា "ប្រពៃណី" របស់ខ្លួន ចាប់តាំងពីសម័យអាណានិគមនិយម និងជាពិសេសក្នុងអំឡុងរបបខ្មែរក្រហម។ លើសពីនេះទៀត កម្មវិធីដែលព្យាយាមបណ្តុះបញ្ញាជនដោយការនាំចូលនូវចំណេះដឹងបែបបស្ចិមប្រទេស មិនអាចជួយអ្វីបានទេ គឺបានតែនាំឲ្យអ្នកគិតខ្មែរឃ្លាតកាន់តែឆ្ងាយពីសង្គមរបស់ខ្លួនថែមទៀត។ ជាយថាហេតុ នាពេលនេះ ពលរដ្ឋកម្ពុជា បរាជ័យក្នុងការទទួលស្គាល់ភាពទទេនៃសុភមង្គលបែបអំពិលអំពែកខាងសម្ភារនិយម។ អ្វីដែលធ្ងន់ធ្ងរជាងនេះទៅទៀត ពួកគេព្យាយាមបំពាក់នូវការបង្កប់គ្រាប់ពូជដែលមិនមានអត្ថន័យសម្រាប់ជីវិត — ភាពឥតន័យ — ក្នុងស្រមោលនៃការស្វែងរកភាពល្អខាងសម្ភារនិយម មុខមាត់ និងអំណាចឥទ្ធិពល។ ទោះជាក្តីសង្ឃឹមមានតិចតួចក៏ដោយ ភាពទទេ និងភាពឥតន័យនេះ ប្រសិនបើបានឆ្លងកាត់ទស្សនវិជ្ជា និងឆ្លុះបញ្ចាំងតាមរយៈពុទ្ធសាសនា គំនិតបែបអត្ថិភាពនិយម និងបាតុភូតនិយម អាចជាប្រភពដែលប្រកបដោយសក្តានុពលសម្រាប់ការរស់ឡើងវិញ និងការចាប់កំណើតជាថ្មីរបស់កម្ពុជា។ អ្វីដែលត្រូវការនោះគឺគំនិតទាំងឡាយណាដែលអាចបកស្រាយពន្យល់ឡើងវិញតាមទស្សនវិស័យទស្សនវិជ្ជា ហេតុនេះអាចកសាងកម្ពុជាឡើងវិញ ទាំងក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។

មានការសិក្សាតិចតួចណាស់ដែលកើតចេញពីទស្សនវិស័យមនុស្សសាស្ត្រ (រួមទាំងទស្សនវិជ្ជាផងដែរ) កំពុងតតាំងនឹងចក្ខុវិស័យដ៏រឹងមាំអំពី "ការអភិវឌ្ឍ" នៅកម្ពុជា។ ការសិក្សាដែលមានកន្លងមក ភាគច្រើនលើសលុបត្រូវបានសរសេរដោយអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់បរទេស ឬជនជាតិខ្មែរដែលនៅក្រៅប្រទេសមួយចំនួនតូច។ ជាអកុសល ស្នាដៃសំខាន់ៗទាំងនេះ ដែលទទួលឥទ្ធិពលពីបទពិសោធន៍អប់រំរបស់ពួកគេនៅក្រៅប្រទេស ចៀសមិនផុតពីការចាប់ផ្តើម និងបញ្ចប់ជាមួយការបង្កើតតថភាពមួយតាមបែបបស្ចិមប្រទេស ដែលជាញឹកញាប់យល់ពីបញ្ហាសង្គមកម្ពុជាចេញពីកញ្ចក់វែនតាតែមួយ នោះគឺតាមបែបសង្គមអាណាចក្រទំនើប និងអភិវឌ្ឍន៍បែបបស្ចិមប្រទេស។ វាហាក់ដូចជាគ្មានការសិក្សាជាន់ខ្ពស់ហ្មត់ចត់ណាមួយ ដែលត្រូវបានធ្វើឡើងដោយអ្នកស្រាវជ្រាវជាន់ខ្ពស់ "ក្នុងស្រុក" ជាការសិក្សាដែលមានឫសគល់ចេញពីភាសា វប្បធម៌ និងតថភាពផ្សេងទៀត ហើយមានការចូលរួមជជែកវែកញែកយ៉ាងស៊ីជម្រៅដោយប្រើប្រាស់របៀបនៃការគិតតាមបែបប្រពៃណី។ ចេញពីទស្សនវិស័យការបកប្រែវប្បធម៌ លទ្ធផលរបស់វា គឺឯកគំនិតអំពីតថភាពសង្គមកម្ពុជា៖ ដែលការយល់ដឹងនេះច្រើនតែជាចក្ខុវិកលចំពោះមនោសញ្ចេតនា សីលធម៌ និងសភាពនៃអត្ថិភាព ឯកគំនិតនេះបានដាក់កម្រិតដ៏ចង្អៀតអំពីការសន្មតរួចជាស្រេចអំពីអ្វីជាពិភពលោកនេះ។

អ្វីដែលយើងត្រូវការជាដំបូងបំផុត គឺការព្យាយាមបញ្ជាក់ឡើងវិញ ថាតើកង្វះអត្ថន័យ — ភាពឥតន័យ — កើតមានឡើងនៅ

កម្ពុជាដោយរបៀបណា តាមរយៈកញ្ចក់ប្រៀបធៀបពីបទពិសោធន៍របស់ប្រទេសដទៃទៀត។ ជាពិសេស មាគ៌ារបស់កម្ពុជាទៅកាន់ភាពឥតន័យ "ទំនើប" ស្ថិតលើដំណើរការផ្សេងគ្នាទាំងស្រុងពីបស្ចិមប្រទេស។ សង្គមអឺរ៉ុប (បស្ចិមប្រទេស) ចាប់ផ្តើមជាមួយចលនាពន្លឺ (Enlightenment) ការចាប់កំណើតឡើងវិញរបស់វា គឺដោយការបើកទ្វារជាថ្មីទៅកាន់សំណួរបែបទស្សនវិជ្ជាដែលបានកប់បាត់ជាយូរយារណាស់មកហើយ។ ដោយឡែក ចាប់តាំងពីចុងសតវត្សរ៍ទី១៩ នៅពេលដែលប្រព័ន្ធតម្លៃគ្រិស្តសាសនាដែលកំពុងថយចុះ បានពើបប្រទះជាមួយការរីករាលដាលយ៉ាងឆាប់រហ័សនៃលំហទីក្រុង ឧស្សាហកម្ម ការប្រកួតប្រជែងខាងនយោបាយ និងរបៀបរបបរស់នៅថ្មីដែលណែនាំដោយមូលធននិយម បស្ចិមប្រទេសបានតស៊ូជាមួយនឹងបញ្ហាទាំងនេះ នាំទៅដល់ការរួមចំណែកពីសំណាក់ លោក អ៊ីម៉ានូអែល ខាន្ត (Immanuel Kant) លោក ហ្វ្រីឌ្រិស្ត៍ នីឈេ (Friedrich Nietzsche) លោក ម៉ារទីន ហៃឌេហ្គ័រ (Martin Heidegger) និងអ្នកក្រោយរចនាសម្ព័ន្ធនិយមបារាំងផ្សេងទៀត។ ក្នុងករណីកម្ពុជា សំណួរជុំវិញបញ្ហាភាពឥតន័យ ត្រូវបានដាក់សម្ពាធមកលើយើងជាខ្លាំងតាមរយៈឥទ្ធិពលវប្បធម៌បរទេសបីយ៉ាង៖ (១). គំរូស្នែម (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) បែបបស្ចិមប្រទេសនាំមកនូវដោយប្រព័ន្ធអប់រំទំនើប (២). នវសេរីនិយមបែបបស្ចិមប្រទេសនាំមកនូវដោយភ្នាក់ងារម្ចាស់ជំនួយ និង(៣). វប្បធម៌ប្រើប្រាស់និយមនាំមកនូវដោយសេដ្ឋកិច្ចទីផ្សារដែលគ្មានការគ្រប់គ្រងច្បាស់លាស់។

បន្ទាប់មក យើងត្រូវចេញពីការសិក្សាប្រៀបធៀបប្រវត្តិសាស្ត្រទៅឲ្យដល់ការសិក្សាប្រៀបធៀបទស្សនវិជ្ជា។ បញ្ហានេះអាចត្រូវបានរុករកតាមរយៈការបកប្រែអត្ថបទគន្លឹះ និងអ្នកប្រាជ្ញល្បីៗ ដំណើរការប្រែគំនិតទាំងនេះ និងភាពប្រទាញប្រទង់នៃគំនិតគោលទាំងនេះជាមួយនឹង/ក្នុងចំណោមអ្នកប្រាជ្ញទាំងនេះ។ យើងត្រូវតែធ្វើកិច្ចការនេះដោយភ្ជាប់ជាមួយនឹងករណីកម្ពុជា។ គោលបំណងរបស់យើង គឺប្រមូលផ្តុំ និងស្វែងរកធនធានគំនិតដែលអាចបង្កើតបានជាទស្សនវិជ្ជាថ្មីមួយសម្រាប់កម្ពុជា។ ជាឧទាហរណ៍ជាក់ស្តែង គិតពីសព្ទខ្មែរមួយ សន្តិភាវកម្ម ដែលជាបង្កំនៃពាក្យបី សន្តិ (សន្តិភាព) ភាវៈ (ភាវរស់) និងកម្ម (អំពើ)។ សព្ទនេះ សំដៅលើទំនាក់ទំនងរវាងសុភមង្គល សេរីភាព និងទំនាក់ទំនងជាមួយអ្នកដទៃ។ អ្វីដែលយើងសង្ឃឹមថានឹងរុករកឲ្យឃើញ នោះគឺភាពជាប់ទាក់ទងគ្នាដែលសព្ទគន្លឹះទាំងនេះអាចមានជាមួយនឹង "ភាវៈ" របស់លោក ម៉ារទីន ហៃឌេហ្គ័រ ហើយក៏ក្នុងរបៀបដែលវាដាក់សម្ពាធលើទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ (ភាវៈ-ក្នុង-ពិភពលោក-ជាមួយ)។ មានតែការកំណត់សព្ទក្នុងទំនាក់ទំនងជាមួយប្រព័ន្ធទស្សនវិជ្ជាផ្សេងទៀតទេ ដែលកម្ពុជាអាចរកឃើញភាពដូចគ្នា និងឯកលក្ខណៈរបស់ខ្លួនក្នុងពិភពកម្ពុជានាសហសម័យ។

នេះមិនមែនគ្រាន់តែជាលំហាត់បែបការសិក្សាជាន់ខ្ពស់នោះទេ តែវាបានកើតចេញមកពីសកម្មភាពជាក់ស្តែងក្នុងសង្គមកម្ពុជា។ បទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំបង្ហាញថា វាពិតជាដូច្នោះមែន។ រវាងឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០៦ ជីវិតរបស់ខ្ញុំទាំងស្រុង បានផ្តោតលើការសិក្សា និងការបង្រៀនទស្សនវិជ្ជាសំលឹងមើលបញ្ហាដ៏ចាក់ស្រែះកប់ជ្រៅដូចដែលបានលើកយកមកបង្ហាញខាងលើនេះ (តែខ្ញុំសូមសារភាពថា នៅដំណាក់កាលនោះ ខ្ញុំមិនទាន់មានភាពចាស់ទុំនៅឡើយទេ)។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០០៧ ការអប់រំ និងអាជីពការងាររបស់ខ្ញុំ បានប្តូរមកជាអ្នកស្រាវជ្រាវ ជាភ្នាក់ងារអភិវឌ្ឍន៍ និងជាអ្នកដែលសកម្មក្នុងក្រុមការងារកសាងគោលនយោបាយ។ មូលហេតុដែលខ្ញុំសម្រេចចិត្តប្តូរចេញពីទស្សនវិជ្ជាមកកាន់ការអនុវត្តជាក់ស្តែង នោះគឺតម្រូវការចាំបាច់ដែលខ្ញុំគិតថា អាចធ្វើឲ្យខ្ញុំយល់ពីតថភាពកម្ពុជាបានពេញលេញ។

ទោះបីជាយ៉ាងនេះក៏ដោយ ការធ្វើការងារលើបញ្ហារូបវន្តនេះ កាន់តែយូរ បញ្ហាអប់រំ "ដែលមានលក្ខណៈជាក់ស្តែង" ការពិតកាន់តែលេចឡើងយ៉ាងច្បាស់ចំពោះខ្ញុំទៅវិញ នោះគឺសង្គមកម្ពុជាកំពុងអណ្តែតលើមហាសមុទ្របញ្ហាដ៏ជ្រៅមួយ៖ **កម្ពុជាខ្វះមូលដ្ឋានគ្រឹះទស្សនវិជ្ជាក្នុងការធ្វើអ្វីៗគ្រប់យ៉ាង កម្ពុជាបានគ្រាន់តែ "ថតចម្លង" គំរូគំនិតបស្ចិមប្រទេសដែលបានប្រគល់មក *អោយ*[1]តាមរយៈទីផ្សារ និងគោលនយោបាយអភិវឌ្ឍន៍ (អប់រំ) តែប៉ុណ្ណោះ។ វាហាក់ដូចជាគ្មានអ្វីទាល់តែសោះក្នុងការ "ប្រានចោលទៅវិញ" រួចបង្កើតគំនិតថ្មីសម្រាប់កសាង (ឡើងវិញ) នូវទស្សនវិជ្ជាកម្ពុជា ចាប់តាំងពីក្រោយសម័យអាណានិគមនិយម និងរបបខ្មែរក្រហម។ របៀបតែមួយគត់ ដែលអាចបង្កើតបានជាគ្រឹះនៃដំណោះស្រាយនយោបាយជាក់ស្តែងប្រកបដោយចីរភាព នោះគឺការកសាងឡើងវិញតាមបែបទស្សនវិជ្ជា។**

ការសម្រេចចិត្តរបស់ខ្ញុំក្នុងការត្រឡប់មកកាន់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយដើរតួនាទីជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ ចាប់តាំងពីឆ្នាំ២០១៦[2] ជាការពិត ត្រូវបានកំណត់ដោយភាពតានតឹង ដែលចេះតែកើនឡើងរវាងទស្សនវិជ្ជា និងកិច្ចប្រឹងប្រែងបែបប្រតិបត្តិក្នុងការដោះស្រាយបញ្ហារបស់ខ្ញុំ។ វាគឺជាភាពតានតឹងដែលមិនគ្រាន់តែកើតមានចំពោះខ្ញុំជាបុគ្គលម្នាក់នោះទេ តែបានរលាយចូលទៅក្នុងលំហគោលនយោបាយទាំងមូលនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន។ ដោយសារតែមូលហេតុនេះហើយ ដែលខ្ញុំមើលឃើញភារកិច្ចបន្ទាន់បំផុតមួយដែលសារជាតិរបស់វាមានលក្ខណៈទស្សនវិជ្ជា ហើយភារកិច្ចបន្ទាន់ដូចគ្នានេះ គឺកំពុងដង្ហើយហៅកម្ពុជាទាំងមូល៖ *ផ្អាកការប្រតិបត្តិផ្នែកគោលនយោបាយជាក់ស្តែងសិន និងត្រឡប់ទៅកាន់ភារៈវិញ។* នេះមានន័យថា យើងមិនអាចជួយកម្ពុជានាសហសម័យបានទេ ដោយគ្មានការស្វែងរក ជដែកវែកញែកឲ្យបានស៊ីជម្រៅ និងកសាងភាពជាខ្មែរតាមបែបទស្សនវិជ្ជាឡើងវិញ។ *ឈរផ្អែកលើជញ្ជាំងបញ្ហាទាំងនេះ និងជាមួយកែវភ្នែកដែលសម្លឹងឆ្ពោះទៅរកការបញ្ជាក់ឡើងវិញអំពីភាពតានតឹងរវាងទស្សនវិជ្ជា និងការប្រតិបត្តិជាក់ស្តែង ដែលខ្ញុំសូមគោរពអញ្ជើញបញ្ញវន្តកម្ពុជាទាំងអស់ ធ្វើការរួមគ្នាលើគម្រោងមួយនេះ។*

បន្ថែមលើការរួមចំណែកក្នុងស្រុក គម្រោងនេះក៏នឹងបង្កើតជាលទ្ធភាពក្នុងការរួមចំណែកពិតប្រាកដក្នុងភាពដើមរបស់ខ្លួនទៅក្នុងទស្សនវិជ្ជាពិភពលោក។ វាមានអ្វីដែលចំណេញច្រើនណាស់ចេញពី*ការសញ្ជឹងគិតអំពីលក្ខខណ្ឌមនុស្ស តាមរយៈការពិនិត្យមើលអត្ថបទបុរាណរបស់ខ្មែរឡើងវិញ និងគិតដើម្បីយល់ពីអត្ថបទទាំងនេះ ដូចដែលអត្ថន័យរបស់វាត្រូវបានគេយល់ជាប្រពៃណី ហើយគិតពីអ្វីដែលមានន័យសម្រាប់សង្គមបច្ចុប្បន្ន*។ គម្រោងនេះចាប់យកមាគ៌ាសន្ទនាជាមួយទស្សនវិទូបស្ចិមប្រទេសអំពីបញ្ហាភារៈ ដើរតាមគំរូដំណើរការកសាងឡើងវិញដ៏ស៊ីជម្រៅដែលបានកើតឡើងនៅប្រទេសជាច្រើននៅអាស៊ីបូព៌ា។ នៅទីនេះ ប្រទេសជប៉ុន គឺជាគំរូស្រាប់ ដែលវាជាកន្លែងមួយ អាចផ្តល់ជាឧទាហរណ៍ថាតើកិច្ចការនេះអាច

[1] "*អោយ*" តាមលោក សរ សារុន ដែលអាចធ្វើឲ្យទៅជានាម "អំណោយ" ដែលអត្ថបទនេះចង់និយាយ គឺ "*អោយ*" ទៅអ្នកដទៃ (សូមមើល ការអធិប្បាយរបស់លោកក្នុងសៀវភៅ "អត្ថាធិប្បាយទស្សនវិជ្ជា៖ ប្រធានបទវប្បធម៌ទូទៅ ប្រធានបទចិត្តវិទ្យា ប្រធានបទសង្គមវិទ្យា ប្រធានបទទស្សនវិជ្ជា" រោងពុម្ពចតុមុខ បោះពុម្ពក្នុងឆ្នាំ១៩៧៤ ទំព័រ១៥៩-១៦០)។

[2] ក្នុងករណីនេះ ខ្ញុំសូមថ្លែងអំណរគុណ មិនគ្រាន់តែចំពោះរាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ តែចំពោះមនុស្សជាច្រើន ជាពិសេស ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន និងឯកឧត្តមបណ្ឌិត ជេត ជាលី ដែលបានគាំទ្រខ្ញុំឲ្យត្រឡប់មកកាន់មហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញវិញ។

ត្រូវធ្វើបានសម្រេចដោយរបៀបណា។ អ្វីដែលជាស្នូលបំផុតនៃគម្រោងនេះ គឺគោលបំណងក្នុងការណែនាំគំនិតទាំងនេះដល់ពលរដ្ឋកម្ពុជា មិនមែនក្នុងន័យធ្វើឲ្យពលរដ្ឋកម្ពុជាទៅជាមនុស្សផ្សេងនោះទេ តែដើម្បីរុករកថាតើយើងអាចកាន់តែក្លាយជាយើងខ្លួនឯងពិតប្រាកដដោយរបៀបណា?

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.com | (+855) 10 950 456
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center